ENERGY AND ENVIRONMENT PARTNERSHIP / MEKONG

MINISTRY FOR FOREIGN AFFAIRS OF FINLAND

# កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គ

# ដំណាក់កាលទី ២ ឆ្នាំ២០១៤ ដល់២០១៨

**កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គ គឺជាផ្នែកមួយនៃកម្មវិធីភាពជាដៃគូផ្នែកថាមពល និង បរិស្ថានពិភពលោក ដែលបានផ្តល់មូលនិធិដោយក្រសួងការបរទេសហ្វាំងឡង់។ កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន ក៏មានផងដែរនៅ អាហ្វ្រិកខាងត្បូង និងអាគ្នេយ៍ តំបន់អង់ឌីន អាមេរិកកណ្តាល និងឥណ្ឌូនេស៊ី ប៉ុន្តែ កម្មវិធីនៅបណ្តាប្រទេសទាំងអស់នេះបានចប់ហើយ។**

កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គ បានចាប់អនុវត្តតាំងពីឆ្នាំ២០០៩។ ដំណាក់កាលទី ១ នៃកម្មវិធីនេះត្រូវបានផ្តល់មូលនិធិរួមដោយក្រសួងការបរទេសហ្វាំងឡង់ និងមូលនិធិអភិវឌ្ឍន៍រឌិកដែលមានទឹកប្រាក់សរុបចំនួន ៧,៩ លានអឺរ៉ូ។ តាមរយៈការប្រកាសទទួលសំណើ កម្មវិធីនេះបានផ្តល់មូលនិធិដល់ការអនុវត្តគម្រោងបានចំនួន៣៩ នៅបណ្តាប្រទេសតាមដងទន្លេមេគង្គទាំង៤៖ កម្ពុជា ឡាវ ថៃឡង់ដ៍ និងវៀតណាម។ គម្រោងទាំងអស់នេះត្រូវបានអនុវត្តដោយអង្គការអភិវឌ្ឍប្រហែល៧៥ (ក្រុមហ៊ុនឯកជន ស្ថាប័ននានា និងសាកលវិទ្យាល័យ ។ល។) ជាពិសេសស្ថិតក្នុងតំបន់ទន្លេមេគង្គ។

តាមរយៈការប្រកាសទទួលសំណើសរុបចំនួន៤លើក អង្គភាពសម្របសម្រួលថ្នាក់តំបន់នៃកម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន បានទទួលសំណើសរុបទាំងអស់ចំនួន ៤៣២។ ដោយឆ្លងកាត់ដំណើរការវាយតម្លៃ និងជ្រើសរើស មានគម្រោងចំនួន៣៩ បានទទួលការគាំទ្រមូលនិធិពីកម្មវិធីភាពជាដៃគូផ្នែកថាមពលនិងបរិស្ថាននេះ។ ចំពោះការប្រកាសទទួលសំណើលើកទី៤ មានគម្រោងចំនួន៧ ដែលបាននិងកំពុងអនុវត្ត ហើយនឹងត្រូវបញ្ចប់ក្នុងអំឡុងឆ្នាំ២០១៥នេះ។ ឥទ្ធិពលនៃកម្មវិធីនេះបានផ្តល់ប្រយោជន៍ដល់អ្នកទទួលផលចំនួន ៥០.០០០ នាក់។ ក្នុងចំណោមគម្រោងចំនួន៣៩ ដែលបានគាំទ្រ មានគម្រោងចំនួន១៣ ត្រូវបានពង្រីកបន្ថែម។

កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គ ដំណាក់កាលទី២ ត្រូវបានគាំទ្រទាំងស្រុងដោយ ក្រសួងការបរទេសហ្វាំងឡង់ ដែលមានទឹកប្រាក់សរុបចំនួន ៩,១លានអឺរ៉ូ។ ការគាំទ្រហិរញ្ញវត្ថុនេះជាផ្នែកមួយនៃគោលនយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាលហ្វាំងឡង់ដែលមានគោលបំណងកាត់បន្ថយភាពក្រីក្រ និងការប្រែប្រួលអាកាសធាតុ តាមរយៈការធ្វើឲ្យទទួលបាននូវការពិតដែលមាននិរន្តរភាពសម្រាប់មនុស្សគ្រប់រូប។

## គោលបំណងនៃកម្មវិធី

កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គ មានគោលបំណងធ្វើឲ្យប្រសើរឡើងនូវការទទួលបាននូវការប្រើប្រាស់ថាមពលដែលមានភាពជឿជាក់ មាននិរន្តរភាព និងមានតម្លៃធូរថ្លៃ ព្រមទាំងជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុលើសកលលោក។

## យុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធី

នៅដំណាក់កាលទី ២ នេះ កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គ នឹងធ្វើសមាហរណកម្ម អភិក្រមផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន និងផ្តល់ហិរញ្ញប្បទានផ្អែកលើលទ្ធផលចូលទៅក្នុងកម្មវិធីរួមរបស់ខ្លួន ព្រមទាំងទៅក្នុងការអនុវត្តគម្រោង។

## ១ ការប្រកាសទទួលសំណើ

មានផែនការប្រកាសទទួលសំណើចំនួន២លើកសម្រាប់ដំណាក់កាលទី២ នៃកម្មវិធីនេះ។ ការផ្តោតលើកិច្ចសហប្រតិបត្តិការពីវិស័យឯកជន ត្រូវបានលើកទឹកចិត្តជាដៃគូអនុវត្តឈានមុខ។ អង្គការក្រៅរដ្ឋាភិបាលដែលមានការសហការ និងមិនរកប្រាក់ចំណេញ សមាគមធុរកិច្ចនានា ។ល។ ក៏អាចដាក់សំណើសុំបានដែរ ប្រសិនបើពួកគេចង់ជាដៃគូសហការក្នុងការអនុវត្តគម្រោងរួមជាមួយ។ និរន្តរភាពនៃគម្រោងថាមពលស្អាតដែលបានស្នើឡើង និងសក្កានុពលនៃការពង្រីកបន្ថែមត្រូវតែរៀបចំឡើងក្នុងផែនការនិងគំរូនៃធុរកិច្ចដែលជាផ្នែកមួយនៃអភិក្រមក្នុងការអនុវត្តគម្រោង។

## ២ ការផ្តល់ហិរញ្ញប្បទានផ្អែកលើលទ្ធផល

រាល់អ្នកលើកគម្រោងទាំងអស់ត្រូវតែបញ្ជាក់ឲ្យបានច្បាស់ថាតើការគាំទ្រពីកម្មវិធីភាពជាដៃគូផ្នែកថាមពល និង បរិស្ថាន តំបន់មេគង្គ នឹងរៀបចំឲ្យមានការអភិវឌ្ឍទីផ្សារទាក់ទងនឹងថាមពលស្អាតដោយរបៀបណា។ ការគាំទ្រពីកម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គនេះ ត្រូវបានផ្តល់ជូន តាមរយៈយន្តការនៃការផ្តល់ហិរញ្ញប្បទានផ្អែកលើលទ្ធផល ដែលបានផ្តល់ឲ្យមានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ បន្ទាប់ពីលទ្ធផលនានា សម្រេចបាន និងផ្ទៀងផ្ទាត់។

## ៣ អភិក្រមផ្អែកលើសិទ្ធិមនុស្ស

កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គ បានដាក់បញ្ចូលអភិក្រមផ្អែកលើសិទ្ធិមនុស្ស និងគោលបំណងអន្តរវិស័យ ទៅក្នុងការរៀបចំផែនការ និងការអនុវត្តគម្រោង។ ការដាក់បញ្ចូលនេះផ្តោតលើបញ្ហា សំខាន់ៗរួមមាន៖ការចូលរួម ការផ្តល់សិទ្ធិអំណាច ការមិនរើសអើង តម្លាភាព គណនេយ្យភាព សមភាពយេនឌ័រ និងនិរន្តរភាពផ្នែកអាកាសធាតុ ក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការអនុវត្តកម្មវិធីនេះ រាប់បញ្ចូលទាំងក្នុងការពិនិត្យ និងវាយតម្លៃពីផលប៉ះពាល់នៃកម្មវិធីផងដែរ។



## ជាតុនានានៃកម្មវិធី

១ ការគៀរគរនូវធនធានថ្នាក់ជាតិ និងតំបន់ក្នុងការអនុវត្តដំណោះស្រាយផ្នែកថាមពលជនបទដែលមាននិរន្តរភាព និងមានតម្លៃធូរថ្លៃ
២ ការគាំទ្រចំពោះការទទួលបាននូវការប្រើប្រាស់ថាមពលកកើតឡើងវិញ នៅតាមតំបន់ជនបទ
៣ ការកសាងសមត្ថភាព និងការផ្លាស់ប្តូរចំណេះដឹងថ្នាក់តំបន់

## រចនាសម្ព័ន្ធនៃការរៀបចំ

កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គ ធ្វើការយ៉ាងជិតស្និតជាមួយក្រសួងនានាដែលធ្វើការ ពាក់ព័ន្ធនឹងថាមពលស្អាត នៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃឡង់ដ៍ និងប្រទេសវៀតណាម។ អ្នកតំណាងមកពីបណ្តាក្រសួងទាំងអស់នោះត្រូវបានតែងតាំងជាសមាជិកនៃគណៈកម្មាធិការដឹកនាំសម្រាប់កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គនេះ។ គណៈកម្មាធិការដឹកនាំកម្មវិធីនេះ នឹងជួបប្រជុំគ្នា២ដង ក្នុង១ឆ្នាំ ដើម្បីផ្តល់ការណែនាំនានា និងការសម្រេចចិត្តសំខាន់ៗ ស្តីពីការអនុវត្តនៃកម្មវិធីនេះ។ ការរៀបចំផែនការ និងការសម្របសម្រួលនៃកម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គនេះ នឹងត្រូវធ្វើឡើង និងគាំទ្រដោយ អង្គភាពសម្របសម្រួលថ្នាក់តំបន់ ដែលមានមូលដ្ឋាននៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។

ការប្រកាសទទួលសំណើនឹងរៀបចំឡើងក្នុងគោលបំណងដើម្បីជ្រើសរើសយកគម្រោងទាំងឡាយណាដែលនឹងផ្តល់ផលប្រយោជន៍ដល់អ្នកទទួលផលបានក្នុងចំនួនច្រើន និងមានធនធានមូលនិធិគ្រប់គ្រាន់របស់ខ្លួនផ្ទាល់។

នៅតាមប្រទេសនីមួយៗ អ្នកសម្របសម្រួលថ្នាក់ជាតិ ដែលមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងអង្គភាពសម្របសម្រួលថ្នាក់តំបន់នោះ មានភារកិច្ចរៀបចំការប្រកាសទទួលសំណើ មានតួនាទីសកម្មក្នុងការពិនិត្យ និងវាយតម្លៃ ព្រមទាំងការកសាងសមត្ថភាព និងការចែករំលែកព័ត៌មាន។

**ទូរលេខស្តីពីកម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន ១**

ប្រទេស៖ ចំនួន **៤**

ថវិកា៖ **៧,៩លានអឺរ៉ូ**

ម្ចាស់ជំនួយ៖ **២**

បានចេញប្រកាសទទួលសំណើ៖ **៤ ដង**

អង្គការដែលបានដាក់សំណើសុំ៖ **៧៥**

សំណើដែលបានដាក់សុំ៖ **៤៣២**

គម្រោងដែលបានផ្តល់មូលនិធិ៖ **៣៩**

អ្នកទទួលផល៖ **៥៤.៧៦៨**

ការពង្រីកបន្ថែម៖ **១៣ គម្រោង**

មូលនិធិដែលបានធានាសម្រាប់ការងារនាពេលអនាគត៖ **១ គម្រោង**

**សម្រាប់ព័ត៌មានបន្ថែម** សូមចូលទៅកាន់វេបសាយ៖ www.eepmekong.org

**អ៊ីម៉ែល**៖ info@eepmekong.org

**អាសយដ្ឋាន**៖

នៅជាន់ទី៦ នៃអាគារវិទ្យាស្ថានលើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញ
ក្រសួងថាមពល និងរ៉ែ
វិថីនងប៊ន ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ

**អាសយដ្ឋានផ្ញើសំបុត្រ**

អង្គភាពសម្របសម្រួលថ្នាក់តំបន់
កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន តំបន់មេគង្គ
ប្រអប់សំបុត្រ លេខ ៤៤០០
ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ